# ព្រះរាជក្រម

នស/រកម/០១៩៦/១២

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ដែលរដ្ឋសភាបានអនុម័តនាសម័យ ប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ:

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

**មាត្រា ១** : ត្រូវបានបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២** : ក្រសួងអភិវឌ្ឍន៍ជនបទ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣** : ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបដែលអាចអមដោយរដ្ឋលេខាធិការ និងឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤** : ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : ច្បាប់នេះត្រូវប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**